# មេរៀនទី៣០៖ យ៉ាកុបរៀបការជាមួយលេអា និងរ៉ាជែល

## [លោកុប្បត្តិ ២៩៖១៥-៣០]

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ [https://youtu.be/gDOtMBWeq74](https://youtu.be/gDOtMBWeq74)

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** [https://youtu.be/Vc6dqnlBTf4](https://youtu.be/Vc6dqnlBTf4)

**គោលចំណង៖** ព្រះធ្វើការនៅគ្រប់ស្ថានភាព

**ខគម្ពីរចងចាំ៖ រ៉ូម៨៖២៨** *"តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នាសំរាប់សេចក្ដីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅមក តាមព្រះដំរិះទ្រង់។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះអង្គនៃយើងទ្រង់ខ្លាំងពូកែ https://youtu.be/VvrF94VKKHA

២. ព្រះយើងជាព្រះអស្ចារ្យ https://youtu.be/TU6HfxJXLvQ

៣. ខ្ញុំថ្វាយបង្គំទ្រង់ https://youtu.be/1C4guXZFdAw

### ១. អធិស្ឋាន

### ២. ចំរៀង

*សូមច្រៀងចម្រៀងដែលមានលីង នៅក្នុងយូធូបលីងខាងលើ*

### ៣. ល្បែងកំសាន្ត « ការល្អកើតចេញពីការអាក្រក់ »

( សំភារៈដែលត្រូវការមាន៖ ថាស១ ដុំថ្ម ខ្សាច់ និងទឹក )




- ❖ ថាស៖ តំណាងឱ្យជីវិត
- ❖ ថ្ម ៖ តំណាងឱ្យការទុកចិត្តលើព្រះ
- ❖ ខ្សាច់ ៖ តំណាងឱ្យការមិនទុកចិត្តព្រះ
- ❖ ទឹក ៖ តំណាងឱ្យរឿងអាក្រក់ដែលអាចកើតមានចំពោះយើង

**គ្រូសួរសំណួរថា** " តើមានការអាក្រក់ណាខ្លះដែលអាចកើតមានចំពោះយើង?" *(ចំលើយអាចជា៖ឪពុកម្ដាយឈ្លោះគ្នា ឬពេលប្រលែងគ្នាជាមួយមិត្តភក្តិធ្វើឱ្យប្អូនមានរបួស)*

- នៅក្នុងថាស ដាក់ថ្មនៅផ្នែកម្ខាង ហើយម្ខាងទៀតដាក់ខ្សាច់

តើប្អូននឹងឈរនៅកន្លែងណា ពេលដែលមានរឿងអាក្រក់កើតឡើងចំពោះប្អូន? (គ្រូនឹងចាក់ទឹក លើគំនរខ្សាច់ហើយបន្ទាប់មកចាក់ទឹកលើថ្ម) តើមានអ្វីកើតឡើងចំពោះខ្សាច់ ហើយនិងថ្ម នៅពេលដែលយើងចាក់ទឹកលើវា(រឿងអាក្រក់នៅក្នុងជីវិត)? ខ្សាច់រាយប៉ាយគ្រប់កន្លែងតែថ្មអត់រង្គើទៅណាទេ! នៅពេលដែលយើងនៅជាមួយព្រះយេស៊ូវយើងអាចរឹងមាំដូចជាថ្មទោះបីជាមាន ការអាក្រក់កើតឡើងនៅក្នុងជីវិតយើងច្រើនប៉ុណ្ណាក៏ដោយ។ ព្រះយេស៊ូវអាចធ្វើឱ្យការល្អកើតចេញពី ការអាក្រក់ទាំងអស់បាន។

### ៤. ការណែនាំពីមេរៀន

ថ្ងៃនេះយើងរៀនពីព្រះជាម្ចាស់ទ្រង់តែងធ្វើការអស្ចារ្យនៅក្នុងគ្រប់ស្ថានភាពទាំងអស់។ វាពិតជាអស្ចារ្យណាស់! ប្រសិនបើនៅថ្ងៃនេះប្អូនសប្បាយចិត្ត ហើយអ្វីៗដែលបានកើតឡើងចំពោះ ប្អូនសុទ្ធតែជារឿង ល្អនោះ។ ប៉ុន្តែបើនៅថ្ងៃនេះប្អូនៗជួបការលំបាក ហើយប្អូនមានអារម្មណ៍មិនសប្បាយចិត្តសូមទុកចិត្ត ព្រះថាទ្រង់មានអំណាច ហើយទ្រង់អាចធ្វើឱ្យមានការល្អកើតឡើងនៅក្នុងស្ថានភាពអាក្រក់របស់យើង។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

យ៉ាកុបបានរត់ចេញពីផ្ទះឪពុករបស់គាត់ គឺអ៊ីសាកបន្ទាប់ពីគាត់បានលួចសិទ្ធិជាកូនច្បងពី បងប្រុសភ្លោះរបស់គាត់គឺអេសាវ។ គាត់បានទៅស្រុកម្ដាយគាត់ហើយរស់នៅទីនោះជាមួយនឹងពូរបស់គាត់ឡាបាន់។ ឡាបាន់មានកូនស្រី ២នាក់ ហើយយ៉ាកុបបានលង់ស្នេហ៍ជាមួយកូនស្រីប្អូនឈ្មោះរ៉ាជែល។ ឡាបាន់បានប្រាប់យ៉ាកុបថា គាត់អាចរៀបការជាមួយនឹងរ៉ាជែលបាន បន្ទាប់ពីយ៉ាកុបធ្វើការឱ្យគាត់បាន៧ឆ្នាំ ដោយសារតែយ៉ាកុបស្រឡាញ់រ៉ាជែលខ្លាំង ទើបគាត់យល់ព្រមតាមសំណើររបស់ឡាបាន់។

ប៉ុន្តែបន្ទាប់ពី៧ឆ្នាំកន្លងផុតទៅ ឡាបាន់ បានប្រើល្បិចជាមួយយ៉ាកុប ជំនួសឱ្យការសន្យារបស់គាត់។ គាត់បានឱ្យយ៉ាកុបរៀបការនឹងកូនស្រីទី១របស់គាត់គឺលេអា ហើយនៅពេលដែលយ៉ាកុបបានដឹងខ្លួនថាគាត់រៀបការខុសមនុស្ស គាត់មានការខកចិត្តយ៉ាងខ្លាំង។ ឡាបាន់និយាយថាយ៉ាកុបអាចរៀបការជាមួយរ៉ាជែលបាន តែត្រូវធ្វើការឱ្យគាត់៧ឆ្នាំទៀត ។

- តើអ្នកចង់ធ្វើការរយៈពេល១៤ឆ្នាំដើម្បីទទួលបាននូវអ្វីដែលអ្នកចង់បានដោយរបៀបណា?
- តើអ្នកធ្លាប់ត្រូវគេសន្យាថាឱ្យអ្វីមួយហើយទទួលបានអ្វីមួយផ្សេងទៀតដែរឬទេ?
- តើអ្នកមានអារម្មណ៍យ៉ាងម៉េចដែរ?

ប្រហែលជាអ្នកត្រូវខកចិត្ត ឬក៏ខឹងដូចជាយ៉ាកុបដែរ។ យ៉ាកុបច្បាស់ជាព្រួយបារម្ភណ៍ថាឡាបាន់នឹងបោកគាត់ម្ដងទៀតបន្ទាប់ពីធ្វើការឱ្យគាត់អស់១៤ឆ្នាំ។ ប៉ុន្តែយ៉ាកុបបានទទួលយកការអាក្រក់ដែលបាន កើតឡើងចំពោះគាត់ ហើយព្រមធ្វើការឱ្យឡាបាន់៧ឆ្នាំទៀត។

ទោះបីជាអ្វីដែលយ៉ាកុបបានជួបជារឿងមិនល្អ ហើយធ្វើឲ្យគាត់ខកចិត្តក៏ដោយ តែព្រះបានកែប្រែវាឱ្យទៅជាព្រះពរវិញ! ព្រះបានប្រទានព្រះពរដល់យ៉ាកុប ឱ្យមានកូនជាច្រើន គឺ កូនប្រុសចំនួន១២នាក់។ កូនៗទាំងអស់របស់គាត់ធំឡើង ហើយមានកូនចៅជាច្រើនបន្តទៀត ហើយព្រះបានប្រើកូនចៅទាំងអស់នោះបង្កើតជាជាតិសាសន៍ដ៏ធំមួយ។ កូនរបស់យ៉ាកុបបានក្លាយទៅជាកុលសម្ព័ន្ធទាំង ១២របស់អ៊ីស្រា - អែល។ កូនចៅរបស់គាត់បានក្លាយជាសាសន៍អ៊ីស្រាអែល យ៉ាកុបត្រូវរង់ចាំអស់ពេលយ៉ាងយូរតែគាត់បានដឹងថា ព្រះធ្វើការអស្ចារ្យនៅក្នុងគ្រប់ស្ថានភាពទាំងអស់។

## ៦. សំនួរពិភាក្សា

១. ជំនួសឱ្យការគិតថាគ្មានព្រះពិត ឬព្រះមិនស្រឡាញ់កូន ពេលដែលមានការអាក្រក់កើតឡើង ចំពោះកូន តើកូនអាចគិតអ្វីពីព្រះ? (*ខ្ញុំអាចគិតថាគ្រប់យ៉ាង ទ្រង់បានធ្វើសំរាប់ខ្ញុំហើយ ខ្ញុំអាចទូលសូមទ្រង់ឱ្យជួយខ្ញុំឆ្លងកាត់វាផុត*)

២. តើកូនបានរៀនអ្វីខ្លះពីស្ថានភាពរបស់យ៉ាកុបដែលអាចជួយកូនបាន? (*ព្រះបានធ្វើការអស្ចារ្យឱ្យកើតឡើង កូនត្រូវតែអត់ធ្មត់*)

## ៧. ខគម្ពីរចងចាំ

**រ៉ូម៨:២៨** *“តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នាសំរាប់សេចក្ដីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅមក តាមព្រះដំរិះទ្រង់”។*

សូមជួយកុមារៗទន្ទេញ ហើយចងចាំខគម្ពីរនេះ

## ៨. ហាត្ថកម្ម

ផាត់ពណ៌ រូបយ៉ាកុប និងកូនប្រុសគាត់ទាំង១២

## ៩. ចំរៀង

*សូមជ្រើសរើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*

## ១០. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
តើក្នុងពេលនេះអ្នកកំពុងតែប្រឈមមុខនឹងការសាកល្បង ឬការលំបាកមែនឬទេ? តើអ្នកនឹងឆ្លើយតបបែបណាចំពោះការលំបាកនោះដើម្បីអ្នកអាចកែប្រែនិងពង្រឹងសេចក្តីជំនឿរបស់អ្នកបាន? បើសិនជាអ្នកកំពុងតែស្ថិនៅក្នុងស្ថានភាពដ៏លំបាក សូមប្រាប់រឿងរ៉ាវរបស់អ្នកទៅកាន់មនុស្សដែល អ្នកទុកចិត្ត ហើយសូមឱ្យម្នាក់នោះលើកទឹកចិត្តអ្នក។ មនុស្សគ្រប់គ្នាតែងជួបនឹងការលំបាកក្នុងជីវិតតែសូមឱ្យអ្នកបានកំសាន្តចិត្តហើយដឹងថាព្រះប្រើការលំបាករបស់យើងជួយ យើងឱ្យរីកចំរើន ហើយធ្វើឱ្យយើងកាន់តែដូចជាព្រះយេស៊ូវ។

# យ៉ាកុប និង កូនប្រុសទាំង ១២



សូមសរសេរខគម្ពីរចងចាំ: ______________________________

__________________________________________________

__________________________________________________

__________________________________________________